**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
## សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងទិវាប្រជាជនពិភពលោក លើកទី៣៦

*សូមក្រាបថ្វាយបង្គំសម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ!*
*សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី !*
*ជនរួមជាតិជាទីស្រឡាញ់រាប់អាន !*

ថ្ងៃនេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមគោរពទូលថ្វាយ និងថ្លែងទៅកាន់សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិទាំងអស់ថា ប្រជាជនកម្ពុជាមានសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានចូលរួមជាមួយនឹងប្រជាជាតិទូទាំងពិភពលោក ប្រារព្ធ «**ទិវាប្រជាជនពិភពលោក លើកទី៣៦**» ក្រោមប្រធានបទ «**ការពង្រឹងភាពអង់អាចដល់ប្រជាជនវ័យក្មេង ក្នុងការបង្កើតគ្រួសារដែលពួកគេប្រាថ្នាក្នុងពិភពលោកមួយដែលមានសមធម៌និងក្តីសង្ឃឹម** (Empowering Young People to Create the Families They Desire in a Fair and Hopeful World)»។ អង្គការសហប្រជាជាតិ បានប្រារព្ធទិវាប្រជាជនពិភពលោក លើកទី១ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩០ ដើម្បីឆ្លើយតបទៅនឹងចំនួនប្រជាជនពិភពលោកដែលបានឈានដល់៥ប៊ីលាននាក់នៅឆ្នាំ១៩៨៧ និងទទួលស្គាល់អំពីតម្រូវការបន្ទាន់ក្នុងការដោះស្រាយបញ្ហាប្រជាជន រួមទាំងការភ្ជាប់ទំនាក់ទំនងរបស់ប្រជាជនទៅនឹងបរិស្ថាននិងការអភិវឌ្ឍ។ ចាប់ពីពេលនោះមក អង្គការសហប្រជាជាតិ តែងលើកទឹកចិត្តដល់បណ្តារដ្ឋសមាជិកទាំងអស់ ឱ្យប្រារព្ធទិវាប្រជាជនពិភពលោក ១១ កក្កដា រៀងរាល់ឆ្នាំ ដោយផ្តោតលើប្រធានបទផ្សេងៗគ្នា។

ការរៀបចំពិធីអបអរសាទរទិវាប្រជាជនពិភពលោកនាថ្ងៃនេះ គឺមិនត្រឹមតែបង្ហាញអំពីការទទួលស្គាល់វឌ្ឍនភាពនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលកម្ពុជាសម្រេចបានប៉ុណ្ណោះទេ ថែមទាំងស្វែងយល់អំពីនិន្នាការ នៃបម្រែបម្រួលប្រជាសាស្ត្រ ជាពិសេសប្រជាជនវ័យក្មេងដែលមានចំនួនច្រើន ហើយពេលនេះប្រជាជនវ័យក្មេងកំពុងមានអនុភាពក្នុងការឆ្ពោះទៅរកការសម្រេចចិត្តនិងជម្រើសដោយខ្លួនឯង ក្នុងការបង្កើតគ្រួសារនិងអនាគតរបស់ខ្លួនប្រកបដោយភាពជឿជាក់និងដោយក្តីសង្ឃឹម។ ប្រជាជនវ័យក្មេង គឺជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍផង និងជាសសរស្តម្ភសម្រាប់ទ្រទ្រង់ការអភិវឌ្ឍផង។ សំខាន់ជាងនេះទៀត ប្រជាជនវ័យក្មេងក៏ជាក្រុមមនុស្សដែលជាកត្តាកំណត់ ចំពោះការកើនឡើង ឬការថយចុះនៃអត្រាលទ្ធភាពមានកូនផងដែរ ពីព្រោះប្រជាជនវ័យក្មេងជាអ្នកសម្រេចចិត្តក្នុងការបង្កើតគ្រួសារនិងចំនួនកូនដែលចង់បាន។

នៅពេលដែលអត្រាលទ្ធភាពមានកូននៅទូទាំងពិភពលោក កំពុងថយចុះដល់កម្រិតទាបខ្លាំងនៅតាមតំបន់មួយចំនួននៃពិភពលោក អ្នកនយោបាយនិងអ្នកវិភាគក្នុងវិស័យព័ត៌មានមួយចំនួន បានបញ្ចេញទស្សនៈព្រួយបារម្ភខ្លាំងអំពី «ការថយចុះនៃចំនួនប្រជាជន» «ការថយចុះខ្លាំងនៃចំនួនប្រជាជន» និងរហូតដល់ «ការផុតពូជរបស់មនុស្ស»។ ប៉ុន្តែ របាយការណ៍ស្ដីពីស្ថានភាពប្រជាជនពិភពលោកឆ្នាំ២០២៥ បង្ហាញថា បញ្ហាពិតប្រាកដមិនមែនជាការថយចុះនៃអត្រាលទ្ធភាពមានកូន ហើយក៏មិនមែនជាចំនួនប្រជាជន៨ប៊ីលាននាក់នៅលើពិភពលោកនាពេលបច្ចុប្បន្នដែរ។ វិបត្តិពិតប្រាកដ គឺកង្វះភ្នាក់ងារសុខភាពបន្តពូជ ដែលជាកង្វះសមត្ថភាពរបស់មនុស្សជាពិសេសគឺប្រជាជនវ័យក្មេងក្នុងការសម្រេចបាននូវសេចក្ដីប្រាថ្នានៃការបង្កើតគ្រួសារ និងការមានកូនរបស់ពួកគេ។ ជាក់ស្ដែង ការស្ទង់មតិរបស់ UNFPA និង YouGov លើមនុស្សជាង១៤ ០០០នាក់ ក្នុង១៤ប្រទេស បានបង្ហាញថាភាគច្រើននៃអ្នកចូលរួមការស្ទង់មតិ មានបំណងចង់មានកូនច្រើន ប៉ុន្តែពួកគេមិនអាចសម្រេចបាននោះទេដោយសារបញ្ហាសង្គម ហិរញ្ញវត្ថុ និងសុខភាព។ ប្រជាជនវ័យក្មេងដែលមានទស្សនៈវិជ្ជមានចំពោះអនាគត មានឱកាសច្រើនក្នុងការសម្រេចអ្វីដែលពួកគេចង់បានសម្រាប់ខ្លួនឯងនិងគ្រួសាររបស់ពួកគេ។ ក៏ប៉ុន្តែ ប្រជាជនវ័យក្មេងភាគច្រើន បានរាយការណ៍អំពីការព្រួយបារម្ភ និងភាពមិនប្រាកដប្រជាចំពោះអនាគតរបស់ខ្លួន ដោយសារបញ្ហាបរិស្ថាន អស្ថិរភាពសេដ្ឋកិច្ច និងការកើនឡើងនៃជម្លោះសកល ដែលនេះក៏ជាឧបសគ្គមួយទៀតដល់ការសម្រេចបាននូវអត្រាលទ្ធភាពមានកូនដែលចង់បាន។

ទោះជាអត្រាកំណើនប្រជាជនពិភពលោកកំពុងថយចុះ ប្រជាជនកម្ពុជានឹងនៅបន្តកើនឡើងក្នុងមួយរយៈពេលវែងទៅមុខទៀត ថ្វីត្បិតតែល្បឿននៃកំណើនកំពុងថយចុះបន្តិចម្ដងៗ។ របាយការណ៍អង្កេតចន្លោះជំរឿនប្រជាជនឆ្នាំ២០២៤ បង្ហាញថា អត្រាលទ្ធភាពមានកូនសរុបនៅកម្ពុជាមានចំនួន២,៥ នៅឆ្នាំ២០២៤។ ការព្យាកររបស់អង្គការសហប្រជាជាតិឆ្នាំ២០២៤ បង្ហាញថា អត្រាលទ្ធភាពមានកូនសរុបនៅកម្ពុជា នឹងថយចុះដល់២,០៤ នៅឆ្នាំ២០៥០។ កម្ពុជាមានប្រជាជនចំនួន១៧,២លាននាក់ នៅឆ្នាំ២០២៤ ដែលនឹងកើនដល់២២លាននាក់នៅឆ្នាំ២០៥០។ ប្រជាជនអាយុ១៥-៥៩ឆ្នាំ មាន៦៣,១% នៅឆ្នាំ២០២៤ ហើយភាគរយនេះនឹងថយចុះតិចតួចដល់ឆ្នាំ២០៥០ គឺ៦១,៧%។ តួលេខនេះ បង្ហាញថា កម្ពុជាមានប្រជាជនស្ថិតក្នុងវ័យកម្លាំងពលកម្មច្រើនរហូតដល់ឆ្នាំ២០៥០ និងក្រោយឆ្នាំ២០៥០ ដែលនេះជាកាលានុវត្តភាពសម្រាប់កម្ពុជាក្នុងការជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!**

ការមានកម្លាំងពលកម្មច្រើន គឺគ្រាន់តែជាឱកាសភាគលាភប្រជាសាស្ត្រប៉ុណ្ណោះ ប៉ុន្តែការវិនិយោគទៅលើការបណ្ដុះបណ្ដាល ភាគលាភប្រជាសាស្ត្រឱ្យមានប្រសិទ្ធភាពនិងទាន់ពេល ទើបជាអត្ថប្រយោជន៍ពិតប្រាកដ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តបង្កើនការវិនិយោគលើប្រជាជនវ័យក្មេងគ្រប់ជំនាន់ តាមរយៈការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិត ការលើកកម្ពស់សេវាសុខភាព ការអភិវឌ្ឍជំនាញបច្ចេកទេស និងការបង្កើតការងារសមរម្យ ដើម្បីកម្ពុជាឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៥០ ជាប្រទេសដែលមានចំណូលខ្ពស់។ ដើម្បីសម្រេចបាននូវចក្ខុវិស័យពោរពេញទៅដោយមហិច្ឆតានេះ យើងចាំបាច់ត្រូវមានគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ច្បាស់លាស់ដែលផ្ដោតលើប្រជាជន ជាពិសេសប្រជាជនវ័យក្មេង ស្ត្រី និងក្មេងស្រី សម្រាប់កសាងសង្គមមួយដែលមានវិបុលភាព និងប្រកបដោយភាពធន់។ ខ្ញុំព្រះករុណា ខ្ញុំសូមឆ្លៀតយកឱកាសនេះ ផ្ដល់នូវសារគន្លឹះដូចខាងក្រោម៖

(១) ក្រសួងផែនការ សហការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំផែនទីបង្ហាញផ្លូវដាក់លាក់ ស្តីពីប្រជាជនដោយផ្អែកលើភស្តុតាង និងការគោរពសិទ្ធិបុគ្គលក្នុងការបង្កើតគ្រួសារនិងចំនួនកូនតាមបំណងប្រាថ្នា។ ការវិនិយោគលើប្រជាជនវ័យក្មេងនាថ្ងៃនេះ ជាពិសេសការវិនិយោគលើការអប់រំ សុខភាព និងការងារ គឺជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍមូលធនមនុស្ស និងការឈានទៅរកវ័យចាស់ប្រកបដោយផលិតភាព។

(២) ក្រសួងផែនការ ត្រូវបន្តរៀបចំទិវាប្រជាជនពិភពលោកឱ្យបានទៀងទាត់រៀងរាល់ឆ្នាំ និងពិភាក្សាជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារគតិយុត្តសម្រាប់បង្កើត «ទិវាជាតិប្រជាជន» ជាផ្លូវការ ឱ្យស្របគ្នាជាមួយនឹង «ទិវាប្រជាជនពិភពលោក»។ សូមឱ្យក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំប្រារព្ធទិវាជាតិប្រជាជននៅតាមស្ថាប័ន និងមូលដ្ឋានរបស់ខ្លួន ដើម្បីក្រើនរំលឹកដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងប្រជាជនគ្រប់រូប គ្រប់វ័យ គ្រប់ជនជាតិ និងគ្រប់សាសនា ឱ្យផ្តោតការយកចិត្តទុកដាក់ និងរួមគ្នាដោះស្រាយបញ្ហាបម្រែបម្រួលប្រជាសាស្ត្រ ដើម្បីកសាងសង្គមជាតិមួយប្រកបដោយភាពធន់ និងប្រកបដោយសុខដុមរមនា។

**ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ!**

ក្នុងនាមប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំមានជំនឿមុតមាំថា ការវិនិយោគលើប្រជាជនវ័យក្មេងនាពេលនេះ តាមរយៈការផ្តល់ឱកាសទទួលបានការអប់រំ ការថែទាំសុខភាព និងការងារសមរម្យ កម្ពុជានឹងទទួលបាននូវវ័យចាស់ដែលមានសុខភាពល្អនិងសកម្មនាពេលអនាគត ដែលជាធនធាននិងទ្រព្យធនជាតិដ៏សំខាន់ក្នុងការចូលរួមកសាងនិងអភិវឌ្ឍប្រទេស។

ខ្ញុំព្រះករុណា ខ្ញុំសូមឆ្លៀតយកឱកាសដ៏មានតម្លៃនេះ ថ្លែងអំណរគុណដល់ជនរួមជាតិទាំងអស់ ដែលបានចូលរួមគាំទ្រនិងរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាលកន្លងមក ក្នុងការកសាងនិងថែរក្សាសន្តិភាព និងសមិទ្ធផលនៃការអភិវឌ្ឍ។ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍទាំងអស់ រួមទាំងស្ថាប័នអង្គការសហប្រជាជាតិ ជាពិសេសមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដែលតែងតែផ្តល់កិច្ចសហការល្អជាមួយនឹងរាជរដ្ឋាភិបាល។

ជាទីបញ្ចប់នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរ ប្រគេនពរ និងជូនពរដល់សម្តេចមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ព្រមទាំងបងប្អូនជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ ចន្ទ ១២កើត ខែ អាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០២៥

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**